# 소망의 여인들

TWR WOMEN OF HOPE

**Prayer Calander** **2024년 1월**

**ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់**




**ការអធិស្ឋានសម្រាប់ស្ត្រីអឺរ៉ុប ១**

ការជួញដូរមនុស្សនៅតែកើតមាននៅក្នុងទ្វីបអឺរ៉ុប ហើយជនដែលរងគ្រោះភាគច្រើនត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ បញ្ហាពិតជាមានការភ្ញាក់ផ្អើលម៉ែនទែន។ ក្រុមការងារស្ត្រីក្នុងក្តីសង្ឃឹមនៅអឺរ៉ុបរបស់យើង កំពុងធ្វើការផ្សព្វផ្សាយអំពីរដំណឹងល្អដល់ស្ត្រីដែលរងគ្រោះពីការជួញដូរទាំងនេះ និងជួយពួកគេឱ្យរួចផុតពីអំពើពេស្យាចារតាមរយៈកម្មវិធីកំណប់អាថ៌កំបាំង ដែលកំពុងផលិតនៅភាគថ្មីៗដែលអាចនាំមកនូវ  ការព្យាបាល និងការស្តារឡើងវិញនៅក្នុងជីវិតរបស់ពួកគេ។ សូមឲ្យពួកគេស្តាប់កម្មវិធីនេះ ហើយអភិវឌ្ឍអត្តសញ្ញាណថ្មីរបស់ពួកគេនៅក្នុងព្រះគ្រីស្ទយេស៊ូវ។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. ព្រះអង្គអើយ សូមអោយស្ត្រីដែលត្រូវបានរំលោភបំពាននៅប្រទេសអាល់បានីមានភាពក្លាហានក្នុងការបង្ហាញមុខអ្នកដែលបំពានលើពួកគេ។ សូមនាំមកនូវការព្យាបាល និងក្តីសង្ឃឹមដែលមានក្នុងព្រះយេស៊ូវដល់ស្ត្រីទាំងនេះ។ (ទំនុកតម្កើង ១៣០:៧)

2. ព្រះអម្ចាស់អើយ សូមផ្តល់ការឆ្នៃប្រឌិត និងគំនិតថ្មីៗដល់ Anja ក្នុងការដែលគាត់ផលិតកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ដែលមានចំណងជើងថា Rise and Shine នៅប្រទេសបែលហ្ស៊ិក។ (ម៉ាថាយ ១០:២០)

3. ឱព្រះជាម្ចាស់អើយ យើងអធិស្ឋានសុំឱ្យកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមត្រូវបានផលិតដោយមានភាពសមប្រកបជាភាសាក្រូអាត ដែលអាចមានការប៉ះពាល់ និងមានភាពទាក់ទាញយ៉ាងខ្លាំងនៅក្នុងដួងចិត្តស្ត្រីនៅទីនោះ។ (ទំនុកតម្កើង ១១៩:១០៥)

4. ឱព្រះវរបិតាអើយ កូនអធិស្ឋានសូមអោយទ្រង់បានទតឃើញ គង់នៅជិត និងជួយសង្គ្រោះស្ត្រីនៅក្នុងប្រទេសដាណឺម៉ាក ដែលរស់នៅក្នុងស្ថានភាពដូចជាទាសករ ត្រូវបានគេកេងប្រវ័ញ្ច និងរស់នៅដោយភាពភ័យខ្លាចជាមួយអំពើហិង្សា។ (លោកុប្បត្តិ ១៦:១៣)

5. ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញាដល់ស្ត្រីជនភៀសខ្លួននៅអឺរ៉ុប នៅពេលដែលពួកគេដៃគូជីវិតរបស់ពួកគេ ទាំងដឹងអាចនឹងមិនកើតឡើងនៅក្នុងប្រទេសចាស់របស់ពួកគេ។ (ទំនុកដំកើង ៣២:៨)

6. បិតាអើយ យើងអធិស្ឋានសម្រាប់ប្រជាជននៃប្រទេសហ្វ៊ីនឡែន ដែលបានបាត់បង់មនុស្សជាទីស្រលាញ់ដោយការធ្វើអត្តឃាត សូមអោយពួកគេបានចូលមករកទ្រង់ដើម្បីទទួលបានការព្យាបាល និងស្វែងរកសន្តិភាពនៅក្នុងដួងចិត្តរបស់ពួកគេជាជាងការរស់នៅជាមួយនឹងការឈឺចាប់ពីការនេះ។ (ម៉ាថាយ ១១:២៨)

7. ព្រះអម្ចាស់អើយ ទូលបង្គំសូមអធិស្ឋានសម្រាប់ស្ត្រីជនជាតិហូឡង់ ដែលរស់នៅជាមួយទុក្ខព្រួយ និងសម្ពាធ គ្រប់ពេលដែលពួកគេប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃនៅលើបណ្តាញសង្គមនានា សូមអោយពួកគេបានរកឃើញតម្លៃពិតប្រាកដរបស់ពួកគេនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ (សុភាសិត ៣:១៥)

8. ព្រះអង្គអើយ សូមប្រទានឧបករណ៍ និងធនធានដែលត្រូវការចាំបាច់ដល់អង្គការដែលធ្វើការជាមួយក្មេងស្រី និងគ្រួសារ ដូចជាជនក្រីក្រ និងប្រជាជនជាច្រើនមកពីប្រទេសប៊ុលហ្គារី និងរូម៉ានី ដែលងាយប្រឈមនឹងការល្បិចដែលនឹងអាចធ្លាក់ខ្លួនក្លាយជាជនរងគ្រោះដោយការជួញដូរមនុស្សនៅទីនោះ។ (២កូរិនថូស ៩:៨)

9. ព្រះវរបិតាអើយ សូមទ្រង់ការពារស្ត្រីនៅប្រទេសបារាំងពីក្រុមមនុស្សដែលបៀតបៀនពួកគេដោយការរំលោភបំពានផ្លូវភេទ។ (ទំនុកតម្កើង ១១៦:៦)

10. ព្រះអង្គអើយ សូមបំផុសគំនិត Stephanie Neeb ដែលជាអ្នកសម្របសម្រួលក្នុងស្រុករបស់ ERF និងព័ន្ធកិច្ចស្ត្រីក្នុងក្តីសង្ឃឹម នៅប្រទេសអាល្លឺម៉ង់ សូមប្រទានអោយគាត់មានគំនិតច្នៃប្រឌិតដើម្បីអោយព័ន្ធកិច្ចនេះមានមនុស្សស្គាល់ និងចូលរួមស្តាប់កាន់តែច្រើន ព្រមទាំងមានម្ចាស់ជំនួយកាន់តែច្រើនផងដែរ។ (ទំនុកតម្កើង ៣៤:១)

11. ព្រះអម្ចាស់អើយ សូមដោះលែងស្ត្រីនៅប្រទេសហូឡង់ពីអំពើរពេស្យាចារ ហើយជួយអង្គការដែលព្យាយាមឈោងចាប់ពួកគេ អោយនាំមកទាំងការលើកទឹកចិត្ត និងសារនៃដំណឹងល្អអំពីព្រះយេស៊ូវ។ (កាឡាទី ៥:១)

12. ព្រះវរបិតាអើយ សូមស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរដែលបានបាត់បង់ និងអត្តសញ្ញាណដ៏ពិតនៅក្នុងព្រះគ្រីស្ទ ដល់ក្មេងស្រី និងស្ត្រីនៅក្នុងប្រទេសម៉ាសេដូន ដែលត្រូវបានចាត់ទុកជាក្រុមមនុស្សថោកទាប។ (រ៉ូម ៨:១៤-១៧)

13. បិតាអើយ តាមរយៈការប្រើរជីវិត និងការរស់នៅជាគំរូដែលកោតខ្លាចព្រះជាម្ចាស់ សូមប្រទានឱ្យអ្នកម្តាយដែលជាគ្រីស្ទាននៅប្រទេសន័រវេសនូវកម្លាំង និងភាពក្លាហាន ក្នុងការចែកចាយដំណឹងល្អអំពីព្រះយេស៊ូវជាមួយកូនៗរបស់ពួកគេជារៀងរាល់ថ្ងៃ។ (ទីតុស ២:៧)


**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 phkorea@twrk.or.kr




14. ឱ ព្រះជាម្ចាស់អើយ
យើងអធិស្ឋានសុំឱ្យផ្នែកវេជ្ជសាស្ត្រនៅក្នុងប្រទេសប៉ូឡូញបានមានភាពប្រសើរឡើង
រួមទាំងសមត្ថភាពក្នុងការធ្វើការវះកាត់មហារីកខួរក្បាលផងដែរ។
អ្នកជំងឺប៉ូឡូញជាច្រើនមិនអាចទៅក្រៅប្រទេសដើម្បីធ្វើការព្យាបាលបានទេ ពីព្រោះវាមានតម្លៃថ្លៃពេក។ (ទំនុកតម្កើង ៤០:៧)

15. អំពើហឹង្សា ការលែងលះ ការរំលោភបំពាន និងរូបភាពអាសអាភាសពិតជាមានផលប៉ះពាល់ដល់ក្រុមគ្រួសារជនជាតិព័រទុយហ្គាល់កាន់តែខ្លាំងឡើងៗ។ ព្រះអម្ចាស់អើយ
សូមនាំមកនូវការស្តារឡើងវិញរបស់ទ្រង់ទៅដល់គ្រប់គ្រួសារដែលខ្ទេចខាត។ (យេរេមា ១៧:១៤)

16. ព្រះអម្ចាស់អើយ
សូមបង្ហាញព្រះវត្តមានទ្រង់ដល់យុវជននៅប្រទេសរ៉ូម៉ានី
សូមឱ្យដួងចិត្តរបស់ពួកគេបានបើកចំហរ
ហើយអោយពួកគេបានស្រឡាញ់ដល់ទ្រង់។
សូមរំដោះពួកគេឱ្យរួចផុតពីគ្រឿងញៀន និងការញៀនអ្វីផ្សេងៗទៀត
ហើយស្តារជីវិតរបស់ពួកគេឡើងវិញផងដែរ។ (ទំនុកតម្កើង ១៨:១៦)

17. ព្រះវរបិតាអើយ
សូមបង្ហាញព្រះវត្តមានទ្រង់ទៅកាន់អស់អ្នកដែលបានឆ្លើយតបទៅនឹងកម្មវិធីដែលក្រុមការងារនៅ North Caucasus របស់យើងបានផលិត។
សូមឲ្យពួកអ្នកស្តាប់ទាំងនេះបានស្គាល់ទ្រង់ក្នុងនាមជាអ្នកដឹកនាំក្រុមរបស់យើង ជាសេចក្តីពិត ជាអ្នកកំសាន្តចិត្ត
និងជាអ្នកគាំទ្រពួកគេផងដែរ។ (រ៉ូម ១៥:១៣)

18. ព្រះជាម្ចាស់
សូមទ្រង់បើកទ្វារសម្រាប់ការសាងសង់ស្ទូឌីយោរបស់ក្រុមស៊ែប៊ីរបស់យើង
នៅពេលដែលពួកគេខិតខំស្វែងរក
ផ្លូវមួយក្នុងការផ្លាស់ប្តូរជីវិតរបស់ស្ត្រីនៅទីនោះ
តាមរយៈការបង្កើតខ្លឹមសារថ្មីៗ និងមានឥទ្ធិពល។ (អេភេសូរ ៣:២០)

19. ព្រះអម្ចាស់អើយ
យើងអធិស្ឋានសម្រាប់ការអនុម័តច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស
នៅក្នុងប្រទេសអេស្ប៉ាញ ដើម្បីការពារក្មេងស្រី
និងស្ត្រីជាច្រើនដែលស្ថិតក្នុងភាពជាទាសករនៃការរំលោភបំពាន
និងកេងប្រវ័ញ្ចផ្លូវភេទ។ (ទំនុកតម្កើង ១០៣:៦)

20. ព្រះវរបិតាអើយ
យើងអធិស្ឋានសម្រាប់កុមារនៅក្នុងសាលារៀននៃប្រទេសស៊ុយអែត
ដែលមានបញ្ហាជាមួយនឹងការបញ្ជាក់អំពីអត្តសញ្ញាណពិតប្រាកដរបស់ពួកគេ
សូមអោយពួកគេមើលឃើញពីតម្លៃរបស់ពួកគេដូចជាព្រះជាម្ចាស់បានឃើញផងដែរ។ (ម៉ាកុស ៨:២៥)

21. សូមការពារ និងពង្រឹងសមាជិកក្រុមការងាររបស់ TWR នៅប្រទេស Ukraine។ បិតាអើយ ទ្រង់ជាព្រះដែលគង់នៅទីនោះ ទ្រង់នឹង បម្រើ
ហើយប្រទានពរដល់ប្រជាជនរបស់ពួកគេផងដែរ។
សូមឲ្យសារនៃសេចក្តីសង្ឃឹមក្នុងព្រះយេស៊ូវបានបន្តផ្សាយ
ហើយបានលឺដល់ស្ត្រីជាច្រើននាក់តាមអ៊ីនធឺណិតផងដែរ។ (អេសាយ ៤០:៣១)

22. ព្រះវរបិតាអើយ សូមនាំមកនូវការរួបរួមនៅក្នុងព្រះវិហារនៃអាល់បានី
ដើម្បីឱ្យសមាជិកបានមានការរួបរួមគ្នា
ដើម្បីឈោងចាប់ប្រទេសរបស់ពួកគេសម្រាប់ព្រះគ្រីស្ទ។ (១កូរិនថូស ១:១០)

23. ព្រះអង្គអើយ
សូមប្រទានពរដល់ការងាររបស់អ្នកសម្របសម្រួលជនជាតិក្រូអាតរបស់យើង ហាណា និងក្រុមការងាររបស់នាង
នៅពេលដែលពួកគេធ្វើការដើម្បីជួយដល់ស្ត្រីពេស្យា និងអ្នកញៀននានា
អោយបានស្វែងរកសេរីភាពនៅមជ្ឈមណ្ឌលបណ្តុះសពរបស់ Zagreb ។
(សុភាសិត ១៤:២១)

24. ព្រះអម្ចាស់អើយ សូមពង្រឹងចំណងអាពាហ៍ពិពាហ៍នៅកោះហ្វារ៉ូ
ដើម្បីឱ្យសេចក្តីស្រឡាញ់ ការគោរព
និងការយកចិត្តទុកដាក់នៅក្នុងទំនាក់ទំនងរបស់ពួកគេ។
សូមការពារពួកគេពីការល្បួងនានារបស់សាតាំង។ (១ពេត្រុស ៤:៨)

25. យើងអធិស្ឋានសម្រាប់ការអភិវឌ្ឍន៍
និងការផ្គត់ផ្គង់សម្រាប់ព័ន្ធកិច្ចប
និងការបម្រើរបស់ក្រុមការងារនៅស៊ែប៊ីរបស់យើង
ដែលធ្វើការជាមួយស្ត្រីរ៉ូម៉ានី។ ព្រះអម្ចាស់អើយ
សូមអោយប្រជាជនរ៉ូម៉ានីដឹង
និងស្គាល់ពីតម្លៃរបស់ពួកគេនៅក្នុងព្រះនេត្ររបស់ទ្រង់។ (យេរេមា ២៩:១១)

26. បិតាអើយ យើងអធិស្ឋានសម្រាប់ការបង្កើតប្រព័ន្ធការពារ
និងគាំទ្រនៅក្នុងប្រទេសន័រវេសចំពោះស្ត្រីដែលជ្រើសរើសរក្សាកូនរបស់ពួកគេ ទោះបីជាពួកគេមានផ្ទៃពោះដោយមិនបានព្រៀងទុកក៏ដោយ។
(កាឡាទី ៦:២)

27. ព្រះអម្ចាស់យេស៊ូវអើយ ទ្រង់តែមួយគត់គឺជាព្រះដ៏ពិត។
សូមទ្រង់បើកបង្ហាញសេចក្តីពិតអំពីទ្រង់
ដើម្បីអោយប្រជាជនប៉ូឡូញបានទទួលស្គាល់
និងថ្វាយបង្គំទ្រង់ជាព្រះពិតតែមួយប៉ុណ្ណោះ។ (ភីលីព ២:៩-១១)

28. បិតាអើយ
សុខភាពផ្លូវចិត្តត្រូវបានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងប្រទេសព័រទុយហ្គាល់ចាប់តាំងពីមានជំងឺកូវីឌ១៩មកម្លេះ ព្រះអម្ចាស់អើយ
សូមឲ្យប្រជាជននៅទីនោះ
មានលទ្ធភាពទទួលបានការថែទាំសុខភាពក្នុងដំណាក់កាលមួយដែលកាន់តែប្រសើរ សូមអោយពួកគេបានយល់ដឹងកាន់តែច្បាស់អំពីជំងឺ
និងមិនមានភាពខ្មាស់អៀនក្នុងការសុំជំនួយផងដែរ។ (ភីលីព ៤:៦-៧)

29.សូមពង្រឹងសេចក្តីជំនឿរបស់ស្ត្រីដែលជាម្តាយគ្រីស្ទបរិស័ទនៅប្រទេសរ៉ូម៉ានី បិតាអើយ
សូមទ្រង់ផ្ទៀងព្រះការស្តាប់គ្រប់សេចក្តីអធិស្ឋានរបស់ពួកគេ
ដែលអង្វរសុំអោយសមាជិកក្រុមគ្រួសាររបស់ពួកគេទទួលបានសេចក្តីសង្គ្រោះពីព្រះយេស៊ូវ។ (១ពេត្រុស ៣:១-៦)

30. ព្រះវរបិតាអើយ សូមទ្រង់ធ្វើជាទីពឹង
និងជំនួយដល់ក្មេងស្រីនៅប្រទេសអេស្ប៉ាញ។
សូមឱ្យពួកគេទទួលបានការការពារពីការរំលោភបំពានដ៏ឃោរឃៅ
និងរួចផុតពីអំពើហិង្សានានាផងដែឬ។ (២សាំយូអែល ២២:៣-៤)

31. ព្រះបិតា ដែលគង់នៅស្ថានសួគ៌អើយ
សូមប្រទានពរដល់បងប្អូនស្រីៗជនជាតិអ៊ុយក្រែនរបស់យើង
ដែលកំពុងរស់នៅជាមួយសង្គ្រាម
សូមអោយការបកប្រែប្រតិទិនអធិស្ឋាននៅតែបន្តធ្វើទៅជាភាសារុស្ស៊ី
សម្រាប់ប្រជាជនអ៊ុយក្រែន រុស្ស៊ី និងអាស៊ីភាគកណ្តាល។ (យេរេមា ១៧:៧-៨)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**